ក №25/15 ➜ 04/4/2015

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១២-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២០៣ ស្តីពី ការតម្លើងថ្នាក់ជូនមន្ត្រីរាជការ ចំនួន ០៤ រូប នៃក្របខ័ណ្ឌមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ២៩៧៨

២៣-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៣១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ឧបាសក និងឧបាសិកា ចំនួន ២២២ រូប ២៩៧៩

២៥-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៣២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចូវ វៃហ័រ** (ZHOU WEIHUA) ជនជាតិចិន សញ្ជាតិចិន ២៩៨៣

២៥-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៣៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ស៊ុង ចាវប៊ិន** (SONG ZHAOBIN) ជនជាតិចិន សញ្ជាតិចិន ២៩៨៤

២៥-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៣៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និងអស់លោកជាជនបរទេស ចំនួន ២៥ រូប ២៩៨៥

២៥-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៣៥ ស្តីពី ការតែងតាំងឯកឧត្តម **ឡាយ វីរៈ** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ ២៩៨៧

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៣៨ ស្តីពី ការផ្ទេរក្របខ័ណ្ឌ និងតែងតាំងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ទោ ជូនលោក **ខិន ឋានណាល់** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ២៩៨៨

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៣៩ ស្តីពី ការផ្ទេរបញ្ចូល និងតម្លើងឋានន្តរស័ក្តិ ជាករណីពិសេសដល់លោកស្រី **ញឹក សាគន្ធ** នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ក្រសួងសុខាភិបាល ២៩៨៩

៣១-៣-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៣១៥/២៤០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជូននាយនគរបាល ជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ១០ រូប ២៩៩០

# II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៩ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៨០.២៩៥ ម៉ែត្រក្រឡា ស្ថិតក្នុងភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ចេញពីបឹងតាមោក (បឹងកប់ស្រូវ) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូននាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច ២៩៩១
៣១-៣-២០១៥ -អនុក្រឹត្យលេខ ៤០ អនក្រ.បក ស្តីពី ការកែសម្រួលតារាងពន្ធតែមប្រិ៍សារពើពន្ធ ២៩៩៣
០១-៤-២០១៥ -អនុក្រឹត្យលេខ ៤១ អនក្រ.បក ស្តីពី ការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ២៩៩៨
២៤-៣-២០១៥ -អនុក្រឹត្យលេខ ៣២៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣០០១
២៤-៣-២០១៥ -អនុក្រឹត្យលេខ ៣២៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣០០៣
២៤-៣-២០១៥ -អនុក្រឹត្យលេខ ៣២៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣០០៥
២៤-៣-២០១៥ -អនុក្រឹត្យលេខ ៣២៧ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៣០០៦
២៤-៣-២០១៥ -អនុក្រឹត្យលេខ ៣២៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣០០៧
២៤-៣-២០១៥ -អនុក្រឹត្យលេខ ៣២៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣០០៨
២៥-៣-២០១៥ -អនុក្រឹត្យលេខ ៣៣០ អនក្រ.តត ស្តីពី ការសម្រួលភារកិច្ច តែងតាំង និងប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ ៣០១០
២៥-៣-២០១៥ -អនុក្រឹត្យលេខ ៣៣១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣០១២
២៥-៣-២០១៥ -អនុក្រឹត្យលេខ ៣៣២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣០១៣
២៥-៣-២០១៥ -អនុក្រឹត្យលេខ ៣៣៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីនគរបាលជាតិ ៣០១៤
២៥-៣-២០១៥ -អនុក្រឹត្យលេខ ៣៣៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣០១៥
២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៣៥ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៣០១៦
២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៣៦ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៣០១៨
២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៣៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣០១៩
២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៣៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣០២០
២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៣៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣០២១
២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៤០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣០២៨

២៦-៣-២០១៥ -អនុក្រឹត្យលេខ ៣៤១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៣០៣៤


## ២.សេចក្តីសម្រេច


២៧-៣-២០១៥ -សេចក្តីសម្រេចលេខ ២៤ សសរ ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ៣០៣៥


## III.ការងារបណ្តាក្រសួង

## ១.ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១៣-៣-២០១៥ -ប្រកាសលេខ ២៨០ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទានរង នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៣០៣៨

១៣-៣-២០១៥ -ប្រកាសលេខ ២៨៦ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន នៅក្រសួងមុខងារសាធារណៈ ៣០៤២

០៥-៣-២០១៥ -សារាចរលេខ ០០៣ សហវ ស្តីពី ការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៤ និងបទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ សម្រាប់ឆ្នាំ ២០១៥ ៣០៤៤


## ២.ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម


១២-០១-២០១៤ -ប្រកាសលេខ ០០៥ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជេនធើន អេនធើប្រាយ បង្កើតរោងចក្រផលិត សម្លៀកបំពាក់ (បោះពុម្ព), សម្លៀកបំពាក់ (ប៉ាក់) ៣០៨៦

១២-០១-២០១៥ -ប្រកាសលេខ ០០៦ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាង កាងបាយអូខេមីខល បង្កើតរោងចក្រផលិត អាល់កុល, ម្សៅសូដ្យូមស៊ីត្រាត ៣០៩០

២៦-០១-២០១៥ -ប្រកាសលេខ ០២៣ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សុន ស៊ុយស៊ីង អ៊ិនដាសស្ទ្រៀល (ខេមបូឌា) បង្កើតរោងចក្រផលិត កាបូបគ្រប់ប្រភេទ ៣០៩៤

២៦-០១-២០១៥ -ប្រកាសលេខ ០២៤ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អរិន មេនូហ្វេកឆឺរីង (ខ្មែរ ) បង្កើតរោងចក្រផលិត សម្លៀកបំពាក់ (ចាក់) ៣០៩៨

២៦-០១-២០១៥ -ប្រកាសលេខ ០២៥ ឧស.កឧ.ប្រក.០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វូខឺស មេត (ខេមបូឌា) លេឌើ ហ្គូដ មេនូហ្វេកឆឺរីង លីមីធីត បង្កើតរោងចក្រផលិត កាបូបគ្រប់ប្រភេទ ៣១០២

## ៣-ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១២-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៩១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អ៊ិនហ្វូខឹស (ខេមបូឌា) ខបភើរេសិន អិលធីឌី** ៣១០៦

១៣-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៩៣ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតម្កល់ទុក លក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ជុងភាង ស្ទីល ស្ត្រាក់ឈ័រ (ខេមបូឌា)** ៣១០៨

១៣-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៩៤ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ជី ឆាន** ៣១១០

១៣-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៩៥ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការបង្កើត សាខាក្រុមហ៊ុន **ស៊ីដាប់បែលយូធី ខឹមម៉ឌិធី (ខេមបូឌា)** ៣១១១

១៣-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៩៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ណារ៉ាឆយ ឡាក់ស៊ី** ៣១១២

១៣-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៩៧ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **មេគន្ធ ស៊ីដ ខូ អិលធីឌី** ៣១១៤

១៣-០១-២០១៥ -លិខិតបញ្ជាក់លេខ ០២៩៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **វ៉ាយដ៏ អេកស្ព្រីឌីសិន ខូ អិលធីឌី** ៣១១៦

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៧២៥ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី ៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តម្លើងថ្នាក់ជូនមន្ត្រីរាជការ ចំនួន ០៤ រូប នៃក្របខ័ណ្ឌមន្ត្រីរាជការ នៃក្រុមនីតិបញ្ញត្តិ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | អ៊ុំ រិល | ពីឧត្តមអភិបាល ថ្នាក់លេខ ៣ | ទៅជាឧត្តមអភិបាល ថ្នាក់លេខ ២ |
| ២- ឯកឧត្តម | ចាន់ សុចច្ឆនា | ពីឧត្តមអភិបាល ថ្នាក់លេខ ៣ | ទៅជាឧត្តមអភិបាល ថ្នាក់លេខ ២ |
| ៣- ឯកឧត្តម | ស៊ិន ចិត្រា | ពីឧត្តមអភិបាល ថ្នាក់លេខ ៦ | ទៅជាឧត្តមអភិបាល ថ្នាក់លេខ ៥ |
| ៤- ឯកឧត្តម | ម៉េង ផល្លា | ពីឧត្តមអភិបាល ថ្នាក់លេខ ៦ | ទៅជាឧត្តមអភិបាល ថ្នាក់លេខ ៥ |

មាត្រា ២ : ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥*

**គ្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ចរាចរ.១៥០៣.២០៤

លេខៈ ២៥៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៣១

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**
ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១- ឯកឧត្តម **ភួង ម៉ាល័យ**
២- ឯកឧត្តម **ព្រហ្ម ចាន់សុខា**
៣- ឯកឧត្តម **នង ឌីណា**
៤- ឯកឧត្តម **ចាន់ គីមសេង**
៥- លោកជំទាវ **ឈរ សៀកហ៊្លុយ**
៦- លោកជំទាវ **ផាន់ ប៊ុនសត្ថាវ៉ាន់**
៧- លោក **ជា ចំរើន**
៨- លោក **សក្តជា វីរៈ**
៩- លោក **សេង សំណាង**
១០- លោក **សុខ សោភ័ណ្ឌ**
១១- លោក **ពីម វុទ្ធិន**
១២- លោក **ហង្ស សិរីរតនៈ**
១៣- លោក **ងី សុខគីមរ៉េន**
១៤- លោក **ម៉ែន យ៉ា**
១៥- លោក **ផន សភា**
១៦- លោក **លុក អ៊ីន**
១៧- លោក **មាស សំណាង**

៣៣- លោក **ឃីម សាវុន**
៣៤- លោក **ប៊ុល និលឯក**
៣៥- លោក **ផាង សុវិរៈ**
៣៦- លោក **ឡាយ សំណាង**
៣៧- លោក **ម៉ៅ សុភារម្យ**
៣៨- លោក **ជិន វណ្ណា**
៣៩- លោក **ឈ្លាង រិទ្ធ**
៤០- លោក **ប្រាក់ សាវុន**
៤១- លោក **វិន សុខសីលាលីដា**
៤២- ឧបាសក **ស៊ិន យួន**
៤៣- ឧបាសិកា **អាំ សំបូរ**
៤៤- លោក **ថៃត ពិសាល**
៤៥- លោក **ពៅ សុផាត**
៤៦- លោក **អ៊ុក សុភ័ក្ត្រា**
៤៧- លោក **ស៊ុង សុខតារ៉ាត់**
៤៨- លោក **ស៊ីវ សុវណ្ណារ៉ា**
៤៩- លោក **សេង វិសាល**

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

១៨- លោក ឡេង រតនា
១៩- លោក សួស សុខ
២០- លោក សុខ ហ៊ត់
២១- លោក ម៉ៅ រិទ្ធ
២២- លោក សរិត បូរ៉ា
២៣- លោក ឧត្យ គីរក្ស
២៤- លោក តេង សុភា
២៥- លោក ស៊ិន ចំរើន
២៦- លោក សោម សុផល
២៧- លោក ស៊ាម គីមឈាង
២៨- លោក លីម វណ្ណីដា
២៩- លោក ហង្ស សិរីរតនៈ
៣០- លោក អ៊ុក ទីរៈ
៣១- លោក រស់ សុធី
៣២- លោក លាង កែវពិសិដ្ឋ
៥០- លោក សៅ ផល្លា
៥១- លោក លាង លីមនាង
៥២- លោក ផូ អឿន
៥៣- លោក ឈឹម ធីដា
៥៤- លោក ប៊ុក ហាក់
៥៥- លោក យ៉ាន់ លួង
៥៦- លោកស្រី ទេព កុលាប
៥៧- លោក ស្តើង សារិទ្ធ
៥៨- លោក កែវ សុភល
៥៩- លោក ហួន ចាន់រតនៈ
៦០- លោក អ៊ឹង ប៊ូហេង
៦១- លោក អាន លីអ៊ាង
៦២- លោក ឡឹក សុភា
៦៣- លោក ម៉ៅ សំអឿន

ខ- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១- លោកជំទាវ ម៉ៅ នរូរ័ត្ន
២- លោកជំទាវ នាង សុវណ្ណារ៉ា
៣- លោក យ៉ាង វណ្ណា
៤- លោក យឿន សុភារៈ
៥- លោកស្រី ឌី សត្យា
៦- លោក សេង សុគន្ធ
៧- លោក ប្រាជ្ញ សោភ័ណ្ណា
៨- លោក យឹម សារ៉ាន់
៩- លោកស្រី ញៀម ច័ន្ទនី
១០- លោកស្រី ឌី សិទ្ធីតា
១១- Ms. MAO DARASINATH
១២- Mr. SOVANTHA HENG
១៣- លោក មិន សុផេត
១៤- លោក ញៀម ផូ
១៥- លោក យឹម សុជាតិ

ឃ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១- ឯកឧត្តម ង៉ែត ច័ន្ទថា
២- ឯកឧត្តម ឃៀង សុគន្ធា
៣- ឯកឧត្តម គៀង ចាន់តួ
៤- ឯកឧត្តម គង់ វិចិត្រ
៥- លោក សោម សុច្ឆារិទ្ធ
៦- លោក ប៊ិច សៀន
៧- លោក ម៉ន សំបុក
៨- លោក ម៉ន ពិសាល
៩- លោក ថោង វណ្ណដា
១០- លោក សរ សិលា
១១- លោក ប៊ុន សុធារ៉ូ
១២- លោក លន ចាន់ថា
១៣- លោក សៀ ទេងកៀង
១៤- លោក សេង រុន
១៥- លោក ហែម វណ្ណា
១៦- លោក ឃួន សុខា
១៧- លោក យឹម រដ្ឋា
១៨- លោក ភង លីដេត
១៩- លោក ប៊ុក សុជាតិ
២០- លោក រ័ត្ន ថាវង្ស
២១- លោក គាង សេង
២២- លោក សៀន វិសាល
២៣- លោក ភួច ធារិទ្ធ
២៤- លោក យី ជួន

ROYAUME DU CAMBODGE · LE MINISTERE DU PALAIS ROYAL

គ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១- លោក **ឈុន វណ្ណី**
២- លោក **លីម សុខលី**
៣- លោក **អ៊ុំ គីមសាន**
៤- លោក **ម៉ុក សុមុន្នី**
៥- លោក **សុខ សុភក្តិ**
៦- លោក **សែម សោភ័ណ**
៧- លោក **ឃីម ចាន់សុផា**
៨- លោក **ឡី សុខសុភាព**
៩- លោក **សួន ភក្តី**
១០- កញ្ញា **ហឿង ដាវី**
១១- លោក **ប៊ុន សារ៉េត**
១២- លោក **សាម៉ាត សារ៉ាវុធ**
១៣- លោក **ឆែ ប៊ុនធុន**
១៤- លោក **កែវ ចិន្តា**
១៥- លោក **ម៉ុំ រុន**
១៦- លោក **ឈិន កំសត់**
១៧- លោក **តាំង ហាំងមេង**
១៨- លោក **ជន ស៊ាងហ៊ំរ**
១៩- លោកស្រី **អ៊ុម ប៊ូរ៉ានី**
២០- លោក **ម៉ុំ ស៊ីណារិទ្ធ**
២១- លោក **នុត សារី**
២២- លោក **ភួង ចំរើន**
២៣- លោកស្រី **ម៉ៅ សៅដា**
២៤- លោក **ហេង បូរិន**
២៥- លោក **ប៉ែន ថុល**
២៦- លោក **ហួន ហុន**
២៧- លោក **គឹម តុលា**
២៨- លោក **អែអន សិតវាសនា**

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា :**

១- ឯកឧត្តម **ហួន ច័ន្ទចេស្តា**
២- លោកសាស្ត្រាចារ្យ **ថោង ស៊ីម**
៣- លោក **ទូន ផាត**
៤- លោក **ស៊ូ សុផល**
៥- លោក **ហ៊ួត ហ្វ្រាកដ**
៦- លោក **ចាត ស៊ូនាង**
៧- លោក **សន សីហា**
៨- លោក **វ៉ែន វិបុល**
៩- លោក **វឿត សុខុន**
១០- លោក **អ៊ុង វ៉ាន់ស៊ុន**
១១- លោកស្រី **ចាន់ គីមចាំ**
១២- លោក **ហេង ចលនា**
១៣- លោកវេជ្ជបណ្ឌិត **សាំង លាង**
១៤- លោក **សាំង ហួត**
១៥- លោក **អ៊ួង វិចិត្រ**
១៦- លោក **គយ រ៉ុម**
១៧- លោក **អែម រាសី**
១៨- លោក **សួង រឹម**
១៩- លោក **ហោ វណ្ណា**
២០- លោក **ហេង សៀកឡាយ**
២១- លោក **ឈូ ស៊ុន**
២២- Dr. SENG BUNTHOEUN
២៣- លោក **ហង្ស ណារិទ្ធ**
២៤- លោក **សុខា សុចិត្រា**
២៥- លោក **សរ យ៉ា**
២៦- លោក **ជា សត្យា**
២៧- លោកស្រី **សុខ ណារី**
២៨- លោក **ពិន ពៅ**
២៩- លោក **អ៊ុង សុផារ៉ាត**
៣០- លោក **ម៉ៅ ប៊ុនថា**
៣១- លោក **ជា សុខ**
៣២- លោក **ឌិន សេង**
៣៣- លោក **ស៊ុយ ចំណាប់**
៣៤- លោក **មិត្ត សំណាង**
៣៥- លោក **អ៊ូ សាវន**
៣៦- កញ្ញា **ប៊ុត ម៉ារ៉ាឌី**
៣៧- លោកស្រី **ញឹម ដាវីតា**
៣៨- លោក **ចាន់ ឫសត្ថី**
៣៩- ព្រះតេជគុណយសលាភោ **រិត ស៊ីធីម**
៤០- លោក **ជៀវ សក្កដា**
៤១- លោក **សុខ ប៉ូរ៉ា**
៤២- ព្រះគុណវិចិត្តោ **ឃីម សុផាត**
៤៣- លោក **នួន ណាន**
៤៤- លោក **សុខ សើម**
៤៥- កញ្ញា **សុផេត សេដ្ឋាវតី**
៤៦- លោក **រុណ វណ្ណារិទ្ធ**
៤៧- លោក **ខៀវ ឌីណា**
៤៨- លោក **សេង ហួរ**

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

ឈ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ :**

១- ព្រះភិក្ខុ **ហេង មុន្នីភាវង្ស**
២- លោក **គោគ ឌី**
៣- លោក **សុខ ដារ៉ា**
៤- លោក **ខាន់ សារឿន**
៥- លោក **យីម ចាន់ទាសនា**
៦- ឧបាសក **ធូ នឿង**
៧- ឧបាសក **អ៊ួន ឈាង**
៨- ឧបាសក **ភន ឈន**
៩- លោក **សុខ ប៊ុនហាក់**
១០- លោក **ស៊ិន អាន**
១១- លោក **គួច មឿង**
១២- លោក **កែវ សុជាតិ**
១៣- លោក **លីម ទិដ្ឋា**
១៤- លោកស្រី **សរ សុខា**
១៥- លោកស្រី **យូ ហឿង**
១៦- លោក **ជា កុណារ៉ា**
១៧- លោក **គីម ឡុង**
១៨- លោក **ភូប ទូលាស់**
១៩- លោក **ជួន រដ្ឋសភា**
២០- លោក **ធេព បូព៌ា**
២១- លោក **ចាន់ សុខា**

ញ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា :**

១- លោក **សេង ម៉េង**
២- លោក **យុត សុខយីម**
៣- លោក **គៅ គីមអាន**
៤- លោក **ស៊ុយ គីមសាន**
៥- លោក **ញ៉ៀម សុខា**
៦- ឧបាសិកា **ទឹម សយ**
៧- ឧបាសិកា **ធាន ឡាំងអេង**
៨- លោក **ឯម សុផាត**
៩- លោក **ហ៊ុន សុជីវ**
១០- លោកស្រី **លីម បូរី**
១១- លោក **និត្យ ណារ៉ុង**
១២- លោក **ម៉ែន សារ៉ាវេត**
១៣- លោក **ដេត ម៉ាប់**

ញ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **សេនា :**

១- លោក **ទ៉ាត់ ច័ន្ទដារ៉ាវត្ត**
២- លោក **សោម ពិសី**
៣- លោក **អោ ប៊ុណ្ណា**
៤- លោក **ញ៉ៀប ឡេង**
៥- លោក **កែ សុវណ្ណថៃ**
៦- លោក **ស្រ៊ុន ស្រឿង**
៧- លោក **ពេជ្ជ សាម៉ោល**
៨- លោក **រ៉េន ជា**
៩- លោក **ចែម ចំណាង**
១០- លោក **អ៊ុំ សារអាត**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

នសរ.១៥០៣.២៣២

លេខ: ២៣៥.ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២៥ ,ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៧២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចូវ វៃហ័រ** ( ZHOU WEIHUA ) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៦៨ នៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន ដោយសុំប្តូរឈ្មោះជា **ចូវ ម៉ុញ ម៉ុញ** ( ZHOU MIN MIN )។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ពរស. ១៥០៣.២៧៣

លេខ: ២៤៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៧៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ុង ចាវប៊ិន** ( SONG ZHAOBIN ) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៦៣ នៅខេត្តសានទុង សាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣រស. ១៥០៣. ២៧៤

លេខៈ ២៤៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៧៤

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

**នូវ**

**ក-គ្រឿងឥស្សរិយយស ជាតូបការ**

-ឯកឧត្ដម ទ៉ាន់ ម៉ាត់

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

១-H.E Pro. Dr. Mehmed GORMEZ

២-Dato΄ Sri Mustapa Mohamed

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

១-H.E. Mr. ILhan Kemal TUG

២-H.E. Mr. Kasmirhan Penggiran Tahir

៣-H.E. Mr. Amjad Ali Sher

៤-H.E Raszlan Abdul Rashid

៥-Datuk Pangiran Mohd Hussein Bin Datuk Pangiran Hj Mohd Tahir Nasruddin

៦-Datuk Seri Ir. Hj Idris Bin Hj Haron

៧-H.E Mr. Abdelilah El Housni

៨-H.E Mr. Jabor Bin Ali Al-Dosari

៩-H.E Salah Ahmed Sarhan

១០-H.E Mr. Mohammed Ali Omran Al Al Shamisi

១១-Datuk Abu Bakar Abdullah

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

១២-Dato´ Abdul Malek Awang Kechil

១៣-Dato´ Abibullah Hj. Samsudin

១៤-Tan Sri Abdul Rashid Bin Abdul Rahman

១៥-Dato´ Ahmad Azam Ab Rahman

១៦-Dato´ Professor Joseph Adaikalam

១៧-Tan Sri Ismee Ismail

១៨-Dato´ Haji Mustafa Abdul Rahman

១៩-YM Raja Saifful Ridzuwan

២០-Syed Azmin Syed Nor

២១-Haji Ismael Abdulkader

២២-Mr. Mustafa TUTKUN

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥
ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ចារ. ១៥០៣.២៧៥

**ហត្ថលេខា និងព្រះរាជលញ្ចករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ: ២៥០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៧៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **ឡាយ ទីរៈ** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខៈ ៤៥១ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៧រស.១៥០៣.២៧៦

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌលោក **ទិន បាណាល់** ពីឋានន្តរស័ក្តិវរៈមន្ត្រីថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ មកក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** តែងតាំងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោក **ទិន បាណាល់** អត្តលេខ **៧៣៧២៧** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

៣១៧.១៥០៣.២៤១

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ: ២៦៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៧៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្ទេរបញ្ចូល និងដំឡើងឋានន្តរស័ក្តិ ជាករណីពិសេសដល់លោកស្រី **ញ៉ឹក សារគន្ធ** ពីឋានន្តរស័ក្តិមន្ត្រីសុខាភិបាលមធ្យមដើមខ្សែ ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម មកឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ក្រសួងសុខាភិបាល ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ចរាច. ១៥០៣.៤៤២

លេខៈ ៤៧៦ ០ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៥/២៤០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ :

**ក. ថ្នាក់ ឧត្តមសេនីយ៍ទោ**

១- លោកឧត្តមសេនីយ៍ត្រី **មាស ច័ន្ទសុផល** អត្តលេខ ០១០៤២
២- លោកឧត្តមសេនីយ៍ត្រី **ទូច សុភា** អត្តលេខ ៦៨១៩៥ ។

**ខ. ថ្នាក់ ឧត្តមសេនីយ៍ត្រី**

១- លោកវរសេនីយ៍ឯក **សុខ ទី** អត្តលេខ ០១៩៥៥
២- លោកវរសេនីយ៍ឯក **មាស ម៉ាលីន** អត្តលេខ ០១៤៦២
៣- លោកវរសេនីយ៍ឯក **សាយ រិទ្ធីសក្តិ** អត្តលេខ ៥៣៩៩៥
៤- លោកវរសេនីយ៍ឯក **ស៊ុម សុជាតិ** អត្តលេខ ៦១៩៩៨
៥- លោកវរសេនីយ៍ឯក **ឡេង គឹមហុង** អត្តលេខ ៥៧៣១៧
៦- លោកវរសេនីយ៍ឯក **ឡេង បូរាណ** អត្តលេខ ០៦០២៤
៧- លោកវរសេនីយ៍ឯក **ស្រ៊ន សំឫទ្ធី** អត្តលេខ ៥៩៧៤៧
៨- លោកវរសេនីយ៍ឯក **ហុង ណារ៉ុង** អត្តលេខ ៦៦៩៥៤ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ពរល.១៥០៣.២៤៣

លេខ:២៦៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា                ជាតិ   សាសនា   ព្រះមហាក្សត្រ

លេខៈ ៣៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ដីទំហំ ៨០.២៩៥ ម៉ែត្រក្រឡា ស្ថិតក្នុងភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ចេញពីបឹងតាមោក ( បឹងកប់ស្រូវ ) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនទាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

### សម្រេច

**មាត្រា ១ ៖** ត្រូវបានកាត់ដីទំហំ ៨០.២៩៥ ម៉ែត្រក្រឡា ស្ថិតក្នុងភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ចេញពីបឹងតាមោក ( បឹងកប់ស្រូវ ) និងធ្វើអនុបយោគជាដី

ឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូននាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាកំណត់ចំនួន ១៨ ចំណុច ដូចខាងក្រោម ៖

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 483728.7524 | 1288534.2851 | 10 | 483956.5842 | 1288264.6437 |
| 2 | 483721.9082 | 1288521.7005 | 11 | 483854.7413 | 1288558.6498 |
| 3 | 483889.9478 | 1287984.1441 | 12 | 483841.3905 | 1288565.6494 |
| 4 | 483901.8278 | 1287977.5328 | 13 | 483722.6442 | 1288529.4020 |
| 5 | 484012.1339 | 1288010.6993 | 14 | 483849.7304 | 1288564.6435 |
| 6 | 484018.5872 | 1288023.0780 | 15 | 483956.5845 | 1288261.4014 |
| 7 | 483944.1321 | 1288249.5517 | 16 | 483944.4299 | 1288253.3766 |
| 8 | 483947.0161 | 1288255.7334 | 17 | 484018.4274 | 1288016.5417 |
| 9 | 483953.7399 | 1288258.4202 | 18 | 483894.2225 | 1287978.6671 |

**មាត្រា ២ ៖** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញ ក្រឹត្យលេខ ២៣ ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតតែមប្រើសារពើពន្ធ

- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធតែមប្រើសារពើពន្ធ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.-**

តារាងពន្ធតែមប្រើសារពើពន្ធ ត្រូវបានកំណត់និងកែសម្រួល ដូចខាងក្រោម÷

**ក. លិខិតគតិយុត្ត**

ពន្ធតែមប្រើសារពើពន្ធ ត្រូវអនុវត្តចំពោះលិខិតគតិយុត្ត តាមប្រភេទ និងអត្រា ដូចខាងក្រោម÷

| **លេខរៀង** | **ប្រភេទលិខិត** | **អត្រាពន្ធ** |
|---|---|---|
| ១ | លិខិតស្នើសុំចូលរៀនមធ្យមសិក្សា | 0 ៛ |
| ២ | លិខិតស្នើសុំប្រឡងយកសញ្ញាបត្រ | 0 ៛ |
| ៣ | លិខិតស្នើសុំចូលរៀន និង ប្រឡងចូលរៀននៅគ្រឹះស្ថានអប់រំ ឬសាលាបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងនិងក្រៅប្រទេស | 0 ៛ |
| ៤ | លិខិតស្នើសុំចូល និង ប្រឡងចូលធ្វើការ | 0 ៛ |
| ៥ | លិខិតថ្កោលទោស | 0 ៛ |
| ៦ | លិខិតស្នើសុំប្រឡងបើកបររថយន្ត/ ជលយានយន្តគ្រប់ប្រភេទ | 0 ៛ |
| ៧ | លិខិតស្នើសុំចូលដេញថ្លៃឡូតិ៍នេសាទ-ព្រៃគុប | 0 ៛ |
| ៨ | លិខិតស្នើសុំបង្កើតក្រុមហ៊ុន អាហារ៉ណ-នីហារ៉ណ សណ្ឋាគារ វិនិយោគទុនបរទេស | 0 ៛ |
| ៩ | លិខិតស្នើសុំប្រកបអាជីវកម្មផ្សេងៗ | 0៛ |
| ១០ | លិខិតស្នើសុំផ្តល់ស្លាកលេខសម្គាល់យានយន្ត/ ជលយានយន្តគ្រប់ប្រភេទ | 0 ៛ |
| ១១ | លិខិតស្នើសុំផ្សេងៗ | 0 ៛ |
| ១២ | ពាក្យបណ្តឹងគ្រប់ប្រភេទ | 0 ៛ |
| ១៣ | លិខិតបញ្ជាក់កិរិយាមារយាទ ប្រវត្តិរូប<br>បញ្ជាក់ទីលំនៅ "ដើម ឬ ចម្លង" | 0 ៛ |

| | | |
|---|---|---|
| ១៤ | សំបុត្រកំណើត "ដើម ឬ ចម្លង" | ០ រ |
| ១៥ | សំបុត្រមរណភាព "ដើម ឬ ចម្លង" | ០ រ |
| ១៦ | សំបុត្រអាពាហ៍ពិពាហ៍ "ដើម ឬ ចម្លង" | ០ រ |
| ១៧ | លក្ខន្តិកៈក្រុមហ៊ុនអាជីវកម្មនានា "ដើម ឬ ចម្លង" | ០ រ |
| ១៨ | ប័ណ្ណសម្គាល់ត្រីចក្រយាន | ០ រ |
| ១៩ | ប័ណ្ណសម្គាល់ត្រីចក្រយានយន្ត | ០ រ |
| ២០ | ប័ណ្ណសម្គាល់ទោចក្រយានយន្ត | ០ រ |
| ២១ | ប័ណ្ណសម្គាល់រថយន្តគ្រប់ប្រភេទ | ០ រ |
| ២២ | ប័ណ្ណសម្គាល់ជលយាន | ០ រ |
| ២៣ | ប័ណ្ណសម្គាល់ជលយានយន្ត | ០ រ |
| ២៤ | ប័ណ្ណបើកបរយានយន្តគ្រប់ប្រភេទ | ០ រ |
| ២៥ | សេចក្តីអនុញ្ញាតឱ្យប្រកបអាជីវកម្មអាហារ៍ណ-នីហារ៍ណ សណ្ឋាគារ វិនិយោគទុនបរទេស | ០ រ |
| ២៦ | សេចក្តីអនុញ្ញាតឱ្យប្រកបអាជីវកម្មផ្សេងៗ | ០ រ |
| ២៧ | លិខិតបញ្ជាក់ លិខិតបកប្រែ | ០ រ |

**ខ. ប័ណ្ណប្រកាស**

ពន្ធតែមប្រើសារពើពន្ធ ត្រូវអនុវត្តចំពោះប័ណ្ណប្រកាស តាមអត្រា ប្រភេទ និងទំហំផ្ទៃក្រឡា ដូចខាងក្រោម÷

| លេខរៀង | ប្រភេទប័ណ្ណប្រកាស | អត្រាពន្ធ | លក្ខខណ្ឌបន្ថែម |
|---|---|---|---|
| **ខ១. ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រដាសធម្មតា** | | | |
| ១ | មានផ្ទៃមិនលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា | ៥០០រ/ទំព័រ | បើមានអក្សរបរទេស ១ ៥០០រ/ទំព័រ |
| ២ | មានផ្ទៃលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា | ៧០០រ/ទំព័រ | បើមានអក្សរបរទេស ២ ១០០រ/ទំព័រ |
| **ខ២. ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រណាត់ ឬវត្ថុ ផ្សេងៗ** | | | |

| | | | | |
|---|---|---|---|---|
| ៣ | មានផ្ទៃមិនលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា | ៧០០៛/ផ្ទាំង | បើមានអក្សរបរទេស ២ ១០០៛/ផ្ទាំង | |
| ៤ | មានផ្ទៃលើសពី ៤០ ដល់ ១០០ ដេស៊ីម៉ែត្រក្រឡា "បើលើសពី ១០០ដេស៊ីម៉ែត្រក្រឡាត្រូវ គិតជាផ្ទាំងអក្សរ" | ១ ០០០៛/ផ្ទាំង | បើមានអក្សរបរទេស ៣ ០០០៛/ផ្ទាំង | |
| **១៣. ស្លាកអាជីវកម្មដ្ឋាននានា** | | | | |
| ៥ | គ្មានពន្លឺលើកស្របដងផ្លូវសាធារណៈ | ១០០៛/ដម$^2$/ឆ្នាំ | ២០០៛ | បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |
| ៦ | គ្មានពន្លឺកែងដងផ្លូវសាធារណៈ | ១៥០៛/ដម$^2$/ឆ្នាំ | ៣០០៛ | |
| ៧ | មានពន្លឺលើកស្របដងផ្លូវសាធារណៈ | ២០០៛/ដម$^2$/ឆ្នាំ | ៤០០៛ | |
| ៨ | មានពន្លឺកែងដងផ្លូវសាធារណៈ | ២៥០៛/ដម$^2$/ឆ្នាំ | ៥០០៛ | |
| **១៤. ផ្ទាំងអក្សរ ឬផ្ទាំងរូបភាព សម្រាប់គោលបំណងពាណិជ្ជកម្ម** | | | | |
| ៩ | គ្មានពន្លឺលើកស្របដងផ្លូវសាធារណៈ | ៥០០៛/ដម$^2$/ឆ្នាំ | ១ ០០០៛ | បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |
| ១០ | គ្មានពន្លឺកែងដងផ្លូវសាធារណៈ | ៧០០៛/ដម$^2$/ឆ្នាំ | ១ ៤០០៛ | |
| ១១ | មានពន្លឺលើកស្របដងផ្លូវសាធារណៈ | ៧០០៛/ដម$^2$/ឆ្នាំ | ១ ៤០០៛ | |
| ១២ | មានពន្លឺកែងដងផ្លូវសាធារណៈ | ១ ០០០៛/ដម$^2$/ឆ្នាំ | ២ ០០០៛ | |
| ១៣ | ដាក់ភ្ជាប់ តភ្ជាប់ ឬគូរផ្ទាល់នឹងមធ្យោបាយដឹកជញ្ជូននានា | ១ ៥០០៛/ដម$^2$/ឆ្នាំ | ៣ ០០០៛ | |

**មាត្រា២.-**

ពន្ធតែមប្រើសារពើពន្ធ មិនអនុវត្តចំពោះប័ណ្ណប្រកាសដែលត្រូវបានផ្សព្វផ្សាយក្នុងគោលបំណងមិនស្វែងរកប្រាក់ចំណេញ ដែលមានជាអាទិ៍ ដូចខាងក្រោម÷

- ស្លាកយីហោសម្រាប់អប់រំសង្គម ការពារបរិស្ថាន ការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ ការការពារព្រៃឈើនិងសត្វព្រៃ ការអប់រំច្បាប់ចរាចរណ៍
- ស្លាកយីហោរបស់អង្គការជាតិ និងអន្តរជាតិ
- ស្លាកយីហោរបស់ស្ថាប័នរដ្ឋ។

**មាត្រា៣.-**

ការអនុវត្តអនុក្រឹត្យនេះ អាចត្រូវបានកំណត់លម្អិត ឬណែនាំបន្ថែម ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤.-**

អនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែលម្អនិងបំពេញបន្ថែមអនុក្រឹត្យស្តីពីការប្រមូលពន្ធតែមប្រើសារពើពន្ធ ត្រូវទុកជានិរាករណ៍។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...៤១...អនក្រ.បក**

# អនុក្រឹត្យ
# ស្ដីពី
# ការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យលេខ១០ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៧/នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្ដីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៨ ស្ដីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១០/៥៩៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ស្ដីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងរៀបចំការបន្ថែមរបបសន្តិសុខសង្គមប្រចាំខែសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជនលើតាវកាលិកការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ ការបាត់បង់សមត្ថភាពការងារ និងពិការភាព។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានគោលដៅដើម្បីកំណត់នូវ៖

- កម្រិតនៃរបបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នលើតាវកាលិកការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ ការបាត់បង់សមត្ថភាពការងារ និងពិការភាព
- ការបន្ថែមរបបសន្តិសុខសង្គមប្រចាំខែលើតាវកាលិកការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ ការបាត់បង់សមត្ថភាពការងារ និងពិការភាព ផ្អែកលើរបបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្ន។

**មាត្រា៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះ៖

- និវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលជាអតីតមន្ត្រីរាជការស៊ីវិល
- និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការដែលជាអតីតយុទ្ធជន
- របបសន្តិសុខសង្គមប្រចាំខែលើតាវកាលិកការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ ការបាត់បង់សមត្ថភាពការងារ និងពិការភាព។

**មាត្រា៤ .-**

ត្រូវបានបន្ថែមរបបសន្តិសុខសង្គមប្រចាំខែសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជនដូចខាងក្រោម៖

កម្រិត១ : របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នទាបជាងឬស្មើ ២៧០ ០០០(ពីរសែនប្រាំពីរម៉ឺន) រៀល ត្រូវបន្ថែមឱ្យដល់ត្រឹម ៣០០ ០០០(បីសែន)រៀលក្នុង១(មួយ)ខែ

កម្រិត២ : របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី ២៧០ ០០១(ពីរសែនប្រាំពីរម៉ឺនមួយ)រៀល ដល់ត្រឹម ៣៩៥ ០០០(បីសែនប្រាំបួនម៉ឺនប្រាំពាន់)រៀល ត្រូវផ្តល់ជូនបន្ថែមចំនួន ៣០ ០០០(បីម៉ឺន)រៀលក្នុង១(មួយ)ខែ

កម្រិត៣ : របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី ៣៩៥ ០០១(បីសែនប្រាំបួនម៉ឺនប្រាំពាន់មួយ)រៀល ដល់ត្រឹម ៤០០ ០០០(បួនសែន)រៀល ត្រូវបន្ថែមឱ្យដល់ត្រឹម ៤២៥ ០០០(បួនសែនពីរម៉ឺនប្រាំពាន់)រៀលក្នុង១(មួយ)ខែ

កម្រិត៤ : របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី ៤០០ ០០១(បួនសែនមួយ) រៀល ដល់ត្រឹម ៤៩៥ ០០០(បួនសែនប្រាំបួនម៉ឺនប្រាំពាន់)រៀល ត្រូវផ្តល់ជូនបន្ថែមចំនួន ២៥ ០០០(ពីរម៉ឺនប្រាំពាន់)រៀលក្នុង១(មួយ)ខែ

កម្រិត៥ : របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នក្នុងចន្លោះចាប់ពី ៤៩៥ ០០១(បួនសែនប្រាំបួនម៉ឺនប្រាំពាន់មួយ)រៀល ដល់ត្រឹម ៥០០ ០០០(ប្រាំសែន)រៀល ត្រូវបន្ថែមឱ្យដល់ត្រឹម ៥២០ ០០០(ប្រាំសែនពីរម៉ឺន)រៀលក្នុង១(មួយ)ខែ

កម្រិត៦ : របបសន្តិសុខសង្គមប្រចាំខែបច្ចុប្បន្នចាប់ពី ៥០០ ០០១(ប្រាំសែនមួយ)រៀលឡើងទៅ ត្រូវផ្តល់ជូនបន្ថែមចំនួន ២០ ០០០(ពីរម៉ឺន)រៀលក្នុង១(មួយ)ខែ។

អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជនដែលបានទទួលការបន្ថែមរបបសន្តិសុខសង្គមប្រចាំខែក្នុងកម្រិតណាមួយខាងលើរួចហើយ មិនអាចទទួលបានកម្រិតផ្សេងទៀតឡើយ។

**មាត្រា៥ ..**

របបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជនប្រចាំខែដែលបានកំណត់ក្នុងមាត្រា៤ ខាងលើ នឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥។

ការកែប្រែកម្រិតនិងរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន ត្រូវធ្វើឡើងដោយអនុក្រឹត្យបន្ទាប់ពីការពិគ្រោះយោបល់រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ។

**មាត្រា៦ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

| រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | រដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ |
|---|---|---|
| **អូន ព័ន្ធមុនីរ័ត្ន** | **វង សូត** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៧៤ .អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ១៧គ្រឿង ប្រគេន និងជូនសប្បុរសជន ចំនួន ១៧រូប ដែលបានបរិច្ចាគបច្ច័យ ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមកសាង ព្រះវិហារ ទទឹង ១៣.១០ម៉ែត្រ បណ្តោយ ២០.១០ម៉ែត្រ កំពស់ ១៧.៥០ម៉ែត្រ សង់លើខឿនកំពស់ ១.១០ម៉ែត្រ របងព័ទ្ធជុំវិញ ទទឹង ២៧.៤០ម៉ែត្រ បណ្តោយ ៣៨.៤០ម៉ែត្រ ខ្លោងទ្វារកំផែង៤ទិស និងជណ្តើរឡើងទៅកាន់ព្រះវិហារ ចំណាយអស់ថវិកាសរុប ចំនួន ២០៥.៤៩១.៦០ ដុល្លារ ស្ថិតនៅក្នុងវត្តពោធិវ័ន្ត(ថ្មសិន) សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | | |
|---|---|---|---|---|
| ១- | ព្រះគ្រូសន្តមនោ | **សុខ ម៉ាន់** | ចៅអធិការស្តីទី បច្ច័យ ១២.០០០ ដុល្លារ | |
| ២- | ព្រះគ្រូ | **ស៊ីុន ទុទ្ធី** | មន្ត្រីសង្ឃ បច្ច័យ ១២.០០០ ដុល្លារ | |
| ៣- | ឧបាសក | **គុំ ហាច** | សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ១២.០០០ ដុល្លារ | |
| ៤- | ឧបាសិកា | **ណា សាយ** | សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ១២.០០០ ដុល្លារ | |
| ៥- | អ្នកស្រី | **ខាំ គិន** | សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ១២.០០០ ដុល្លារ | |
| ៦- | លោក | **ចាន់ ធី** | សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ១២.០០០ ដុល្លារ | |
| ៧- | លោក | **ពោជ ឆា** | សប្បុរសជននៅប៉ោយប៉ែត្រ | ថវិកា ១១.០០០ ដុល្លារ |
| ៨- | លោក | **ព្រំ ធន** | សប្បុរសជននៅប៉ោយប៉ែត | ថវិកា ១១.០០០ ដុល្លារ |
| ៩- | លោក | **ស៊ីុម សារ៉ន** | សប្បុរសជននៅប៉ោយប៉ែត | ថវិកា ១១.០០០ ដុល្លារ |
| ១០- | លោក | **ង៉ាល់ សេដ្ឋា** | សប្បុរសជននៅសង្កាត់និមិត្ត | ថវិកា ១០.០០០ ដុល្លារ |
| ១១- | ឧបាសិកា | **សៀង គីមហួន** | សប្បុរសជននៅប៉ោយប៉ែត | ថវិកា ១០.០០០ ដុល្លារ |
| ១២- | ឧបាសិកា | **ជុំ សំបិន** | សប្បុរសជននៅប៉ោយប៉ែត | ថវិកា ១០.០០០ ដុល្លារ |

ខ-មេដាយប្រាក់ស្ថាបនាជាតិ

| | | | | |
|---|---|---|---|---|
| ១- | លោក | **ឈឿត លាង** | សប្បុរសជននៅប៉ោយប៉ែត | ថវិកា ៦.០០០ ដុល្លារ |
| ២- | អ្នកស្រី | **គង់ សាវុន** | សប្បុរសជននៅប៉ោយប៉ែត | ថវិកា ៦.០០០ ដុល្លារ |
| ៣- | លោក | **ថាន ថេន** | សប្បុរសជននៅប៉ោយប៉ែត | ថវិកា ៦.០០០ ដុល្លារ |
| ៤- | ឧបាសិកា | **ឡាំ សម្បត្តិ** | សប្បុរសជននៅប៉ោយប៉ែត | ថវិកា ៦.០០០ ដុល្លារ |
| ៥- | លោក | **ចុង ជីម** | សប្បុរសជននៅប៉ោយប៉ែត | ថវិកា ៦.០០០ ដុល្លារ |

**មាត្រា ២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ៦៧ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៧៥.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៅខេត្តសៀមរាប ចំនួន ៤៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិកន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

| | | |
|---|---|---|
| ១ | លោក **កែវ ស** | អភិបាលរងស្រុកវ៉ារិន ខេត្តសៀមរាប |
| ២ | លោក **ឡឹក ពឿត** | អភិបាលរងស្រុកអង្គរជុំ ខេត្តសៀមរាប |
| ៣ | លោក **ជ្រា មុនី** | អភិបាលរងស្រុកជីក្រែង ខេត្តសៀមរាប |
